00721133

**Declassified to Public**
**08 April 2021**

លេខ / No: D 26

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

លេខសំណុំរឿង: ០០៣/០៧-០៩-២០០៩/អ.វ.ត.ក./ក.ស.ច.ស.

ការិយាល័យសហចៅក្រមស៊ើបអង្កេត
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 28/07/2011
ម៉ោង (Time/Heure): 13:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

ចំពោះមុខ ៖ ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Siegfried BLUNK

កាលបរិច្ឆេទ ៖ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១១

ភាសា ៖ អង់គ្លេស/ខ្មែរ

ចំណាត់ថ្នាក់ឯកសារ ៖ សម្ងាត់

# ដីកាសម្រេចស្ដីអំពីការដាក់សារាចរថ្មីនូវសំណើសុំបំពេញកិច្ចស៊ើបសួរចំនួនបី របស់សហព្រះរាជអាជ្ញាអន្តរជាតិ នៅក្នុងសំណុំរឿង ០០៣

<u>សហព្រះរាជអាជ្ញា</u>

លោកស្រី ជា លាង

លោក Andrew CAYLEY

00721134

០០៣/០៧-០៩-២០០៩/អ.វ.ត.ក./ក.ស.ច.ស. លេខ/No: D 26

យើង យូ ប៊ុនឡេង និង Siegfried BLUNK (ស៊ីគហ្វ្រីដ ប្លុង) សហចៅក្រមស៊ើបអង្កេតនៃ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក.")

បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០០៤ ("ច្បាប់ស្តីពី អ.វ.ត.ក")

បានឃើញវិធាន ២១ វិធាន ៥៤ វិធាន ៥៥ និង វិធាន ៦៦ នៃវិធានផ្ទៃក្នុងនៃ អ.វ.ត.ក (វិសោធនកម្មលើកទី ៧) ("វិធានផ្ទៃក្នុង")

បានឃើញមាត្រា ៣.១២ នៃសេចក្តីណែនាំអនុវត្តស្តីអំពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក ("សេចក្តីណែនាំអនុវត្ត")

បានឃើញការស៊ើបសួរដែលកំពុងដំណើរការ ស្របតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីររបស់សហព្រះរាជអាជ្ញា

បានឃើញការជូនដំណឹងអំពីការបិទការស៊ើបសួរ ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ (D13)

## I - ការរំលឹកឡើងវិញអំពីនីតិវិធី

១. នៅថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់មកសហចៅក្រមស៊ើបអង្កេតនូវសំណើសុំពេញកិច្ចស៊ើបសួរចំនួនបី ("សំណើសុំ")៖

(i) សំណើបំពេញកិច្ចស៊ើបសួរលើកទីមួយរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ក្នុងសំណុំរឿងលេខ ០០៣ សុំឱ្យទទួលយកឯកសារបន្ថែម និងសេចក្តីសង្កេតលើស្ថានភាពនៃកិច្ចស៊ើបសួរ[1] ។

(ii) សំណើលើកទី ២ របស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបំពេញកិច្ចស៊ើបសួរបន្ថែមពាក់ព័ន្ធនឹងលោក ស៊ូ មេត ព្រមទាំងពាក់ព័ន្ធនឹងទីកន្លែងប្រព្រឹត្តបទល្មើស[2] ។

---

[1] D17 សំណើបំពេញកិច្ចស៊ើបសួរលើកទីមួយរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ក្នុងសំណុំរឿងលេខ ០០៣ សុំឱ្យទទួលយកឯកសារបន្ថែម និងសេចក្តីសង្កេតលើស្ថានភាពនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១ ។

(iii) សំណើបំពេញកិច្ចស៊ើបសួរលើកទីបីរបស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទិននឹង មាស មុត និងទីតាំងឧក្រិដ្ឋកម្មដែលពាក់ព័ន្ធ[3] ។

២. នៅថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១១ សហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចមួយបដិសេធ មិនទទួលយកសំណើសុំទាំងនោះ ដោយហេតុផលខុសនឹងទម្រង់ច្បាប់ ("សេចក្តីសម្រេច")[4] ។

៣. នៅថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់សំណើសុំទាំងនោះឡើងវិញ ("សំណើសុំដែលដាក់ឡើងវិញ") និងបានស្នើសុំដោយអនុលោមតាមវិធាន ៣៩ (៤) ចំពោះសំណើសុំនីមួយៗថា *"សហចៅក្រមស៊ើបអង្កេតទទួលស្គាល់ថាមានសុពលភាព ចំពោះកិច្ចទាំងឡាយណាដែលបានធ្វើក្រោយពីពេលកំណត់ ដែលមានចែងក្នុងវិធាននេះក្នុងនេះត្រូវបានផុតរលត់ ប្រសិនបើខ្លួនយល់ថា ត្រឹមត្រូវសមហេតុផល ។"*[5]

៤. នៅថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតនៅចំពោះមុខអង្គបុរេជំនុំជម្រះ ("អ.ប.ជ")[6] ។ ក្រៅអំពី

---

[2] D18 សំណើលើកទី ២ របស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបំពេញកិច្ចស៊ើបសួរបន្ថែមពាក់ព័ន្ធ នឹងលោក ស៊ូ មេត ព្រមទាំងពាក់ព័ន្ធនឹងទីកន្លែងប្រព្រឹត្តបទល្មើស ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១ ។

[3] D19 សំណើបំពេញកិច្ចស៊ើបសួរលើកទីបីរបស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទិននឹង មាស មុត និងទីតាំងឧក្រិដ្ឋកម្មដែលពាក់ព័ន្ធ ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១ ។

[4] D20/3 ដីកាសម្រេចស្តីអំពីសំណើសុំពន្យាពេលកំណត់ និងសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរស្នើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិ ពាក់ព័ន្ធនឹងសំណុំរឿង ០០៣ ចុះថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១១ ។

[5] D22 សំណើបំពេញកិច្ចស៊ើបសួរលើកទីមួយរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ក្នុងសំណុំរឿងលេខ ០០៣ សុំឲ្យទទួលយកឯកសារបន្ថែម និងសេចក្តីសង្កេតលើស្ថានភាពនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១១ កថាខណ្ឌ ១-៣ ។ D23 សំណើលើកទី ២ របស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបំពេញកិច្ចស៊ើបសួរបន្ថែមពាក់ព័ន្ធ នឹងលោក ស៊ូ មេត ព្រមទាំងពាក់ព័ន្ធនឹងទីកន្លែងប្រព្រឹត្តបទល្មើស ចុះថ្ងៃទី ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១១ កថាខណ្ឌ ១-៣ ។ D24 សំណើបំពេញកិច្ចស៊ើបសួរលើកទីបីរបស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទិននឹង មាស មុត និងទីតាំងឧក្រិដ្ឋកម្មដែលពាក់ព័ន្ធ ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១១ កថាខណ្ឌ ១-៣ ។

[6] D20/4/1 បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ជំទាស់នឹង "សេចក្តីសម្រេចស្តីពីសំណើសុំពន្យារពេលកំណត់ និងសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរស្នើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិ ពាក់ព័ន្ធនឹងសំណុំរឿង ០០៣" ចុះថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០១១ ។

មូលដ្ឋានដែលថា សហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំនៅក្នុងការបដិសេធមិនទទួលយកសំណើសុំដោយហេតុផលមិនត្រឹមត្រូវតាមទម្រង់ច្បាប់ បណ្តឹងឧទ្ធរណ៍ក៏បានលើកឡើងអំពីជម្រើសមួយបន្ថែមទៀតថា *"ការខកខានរបស់ សចស មិនបានពិចារណាលើខ្លឹមសារនៃសំណើទាំងនេះ គឺបានបំពារបំពានដល់កាតព្វកិច្ចតាមផ្លូវច្បាប់របស់ សចស ក្នុងការផ្តល់នូវការស៊ើបសួរមួយដែលមិនលំអៀង និងទាំងស្រុង ។"*[7]

## II - សំអាងហេតុនៃសេចក្តីសម្រេច

៥. បន្ទាប់ពីសហចៅក្រមស៊ើបអង្កេតបានបដិសេធមិនទទួលសំណើសុំ ដោយហេតុផលមិនត្រឹមត្រូវតាមទម្រង់ច្បាប់ សហព្រះរាជអាជ្ញាអន្តរជាតិ ជំនួសឲ្យការដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចដែលការណ៍នេះ គឺជានីតិវិធីដែលត្រឹមត្រូវ[8] បែរជាធ្វើការដាក់សំណើសុំសារជាថ្មី ។ ហើយជាងនេះទៀតសហព្រះរាជអាជ្ញាអន្តរជាតិមិនបានរង់ចាំសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិស្តីអំពីការដាក់សំណើសុំសារជាថ្មីនោះទេ ប៉ុន្តែបែរជាដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចដើមទៅវិញ និងថែមទាំងបានយកជាមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍របស់ខ្លួនទាំងបញ្ហាដែលទាក់ទងនឹងទម្រង់ច្បាប់ និងបញ្ហាដែលទាក់ទងនឹងគតិច្បាប់[9] ។ ហេតុដូច្នេះ អ.ប.ជ កំពុងត្រូវបានប្តឹងអំពីបញ្ហាដែលថាតើសំណើសុំទាំងនោះត្រូវបានធ្វើឡើងដោយត្រឹមត្រូវតាមទម្រង់ច្បាប់ ឬយ៉ាងណា ។ នេះគឺជាសមត្ថកិច្ចផ្តាច់មុខរបស់ អ.ប.ជ ក្នុងការសម្រេចអំពីសុពលភាពនៃសំណើសុំទាំងនេះ ហើយសហចៅក្រមស៊ើបអង្កេតមិនមានសិទ្ធិក្នុងការចូលជ្រៀតជ្រែកចូលក្នុងសមត្ថកិច្ចរបស់ អ.ប.ជ នៅក្នុងបញ្ហានេះឡើយ និងក៏មិនមានសិទ្ធិក្នុងការបង្វែរសមត្ថកិច្ចរបស់ អ.ប.ជ ដោយធ្វើការសម្រេចលើបញ្ហានេះដោយខ្លួនឯងនោះដែរ ។ ការព្យាយាមចោទបញ្ហាឡើងសារជាថ្មីក្នុងរូបភាពជាការដាក់សំណើសុំសារជាថ្មី មិនអាចនឹងលាក់បាំងទេថា បញ្ហាគឺវានៅតែដដែល ។

---

[7] D20/4/1 បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ជំទាស់នឹង "សេចក្តីសម្រេចស្តីពីសំណើសុំពន្យារពេលកំណត់ និងសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរស្នើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិ ពាក់ព័ន្ធនឹងសំណុំរឿង ០០៣" ចុះថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០១១ កថាខណ្ឌ ៩ (គ) (ii) ។

[8] វិធាន ៧៤ (២) ។

[9] កថាខណ្ឌខាងលើ លេខ ៥ ។

០០៣/០៧-០៩-២០០៩/អ.វ.ត.ក./ក.ស.ច.ស. លេខ/No: D ៤៦

៦. សហចៅក្រមស៊ើបអង្កេតយល់ច្បាស់អំពីឆន្ទានុសិទ្ធិរបស់ខ្លួន ដែលផ្តល់ដោយវិធាន ៣៩ នៃវិធានផ្ទៃក្នុង ប៉ុន្តែមិនអាចនឹងអនុវត្តឆន្ទានុសិទ្ធិនេះ តាមការស្នើសុំឡើយ ដោយហេតុថា៖

ក) វិធាន ៦៦ (១) ចែងថា៖

*"នៅពេលដែលសហចៅក្រមស៊ើបអង្កេតយល់ឃើញថា ការស៊ើបសួរត្រូវបានបញ្ចប់ សហចៅក្រមស៊ើបអង្កេតត្រូវជូនដំណឹងដល់គ្រប់ភាគី និងមេធាវីរបស់ភាគី ។ (...) ។ ភាគីទាំងអស់មានរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ដើម្បីសុំឱ្យមានកិច្ចស៊ើបសួរបន្ថែម ។"*

រយៈពេលកំណត់ខាងលើនេះ គឺមានភាពសំខាន់ចាំបាច់ណាស់ ព្រោះថា វាកើតឡើងអំពីគោលការណ៍នៃនីតិវិធី ដែលមានចែងក្នុងវិធាន ២១ *"គោលការណ៍ជាសារវន្ត"* ដែលចែងថា៖

*"៤. ការសម្រេចសេចក្តីលើការចោទប្រកាន់ចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ត្រូវធ្វើការជំនុំជម្រះក្នុងរយៈពេលមួយសមស្រប ។"*

ដើម្បីអនុលោមតាមតម្រូវការនៃភាពឆាប់រហ័សនៃដំណើរការនីតិវិធី សហព្រះរាជអាជ្ញាអន្តរជាតិត្រូវធ្វើការដាក់សំណើសុំឱ្យមានកិច្ចស៊ើបសួរបន្ថែមដែលត្រឹមត្រូវតាមទម្រង់ច្បាប់ ក្នុងរយៈពេលកំណត់ ១៥ ថ្ងៃ ប៉ុន្តែសហព្រះរាជអាជ្ញាអន្តរជាតិបានខកខានមិនបានដាក់ក្នុងរយៈពេលកំណត់នេះ។ ប្រសិនបើមានការតម្រូវឱ្យសហចៅក្រមស៊ើបអង្កេតធ្វើការពន្យាររយៈពេលដែលបានកំណត់ និងត្រូវទទួលស្គាល់សំណើសុំដែលបានធ្វើឡើងដោយមិនត្រឹមត្រូវតាមទម្រង់ច្បាប់ ខណៈដែលសហព្រះរាជអាជ្ញាអន្តរជាតិខកខានមិនបានដាក់សំណើសុំក្នុងរយៈពេលកំណត់ នោះសហចៅក្រមស៊ើបអង្កេតនឹងត្រូវបានចាត់ទុកថា បានរំលោភលើគោលការណ៍ជាសារវន្តនៃនីតិវិធី ។

ខ) ទឡ្ហីករណ៍បន្ថែមចំពោះការណ៍ដែលសហចៅក្រមស៊ើបអង្កេតមិនអាចនឹងអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន តាមការស្នើសុំរបស់សហព្រះរាជអាជ្ញាអន្តរជាតិ៖

វិធាន ៥៥ (១០) ចែងថា៖

*"នៅគ្រប់ពេលវេលានៃការស៊ើបសួរ សហព្រះរាជអាជ្ញា... អាចស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតចេញដីកា ឬបំពេញកិច្ចស៊ើបសួរណាមួយដែលខ្លួនយល់ឃើញថា មានប្រយោជន៍ដល់ការស៊ើបសួរ ។*

ដោយហេតុថា ការស៊ើបសួរនៅក្នុងសំណុំរឿង ០០៣ បានដំណើរការ គឺយ៉ាងហោចណាស់ រាប់ចាប់តាំងពីការចេញដីកាចាត់ឱ្យស៊ើបសួរជំនួសនៅថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១០[10] សហព្រះរាជអាជ្ញាអន្តរជាតិមានរយៈពេលស្ទើរតែពេញមួយឆ្នាំ ដើម្បីស្នើសុំឱ្យមានការបំពេញកិច្ចស៊ើបសួរ ប៉ុន្តែ សហព្រះរាជអាជ្ញាអន្តរជាតិមិនបានជ្រើសយកជម្រើសនេះ រហូតដល់ក្រោយពេលការបិទការស៊ើបសួរ ដោយសហចៅក្រមស៊ើបអង្កេត ដោយអនុលោមតាមវិធាន ៦៦ (១) ។

គ) វានៅមិនទាន់មានភាពច្បាស់លាស់ទេថា សហព្រះរាជអាជ្ញាអន្តរជាតិបានធ្វើការពិចារណាល្អិតល្អន់គ្រប់គ្រាន់អំពីយុត្តាធិការជាមូលដ្ឋាន ដែលបញ្ញត្តនៅក្នុងមាត្រា ២ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. គឺចំពោះលក្ខខណ្ឌដែលថា ជនសង្ស័យនៅក្នុងសំណុំរឿង ០០៣ ត្រូវតែជា "មេដឹកនាំជាន់ខ្ពស់" នៃរបបកម្ពុជាប្រជាធិបតេយ្យ ឬជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងសម័យកាលនោះ៖ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីរ សហព្រះរាជអាជ្ញាអន្តរជាតិបានបង្ហាញថា ខ្លួនមិនអាចនឹងសម្រេចចិត្តថាតើជម្រើសណាមួយក្នុងចំណោមជម្រើសទាំងពីរខាងលើ គួរត្រូវអនុវត្តចំពោះជនសង្ស័យឡើយ ដោយគ្រាន់តែធ្វើការចោទប្រកាន់យ៉ាងសាមញ្ញថា ពួកគេជាមេដឹកនាំជាន់ខ្ពស់ *"និង/ឬ"* អ្នកទទួលខុសត្រូវខ្ពស់បំផុត[11] ។ នៅក្នុងការដាក់សំណើសុំសារជាថ្មី សហព្រះរាជអាជ្ញាអន្តរជាតិបែរជាចាត់ទុកថា ពួកគេជា "មេដឹកនាំជាន់ខ្ពស់"[12] ទោះបីជាថា ការចាត់ទុកមេបញ្ជាការកងពលធំ ដែលចំនួនកងពលធំមានមិនតិចជាង ៩ (បន្ថែម កងវរសេនាធំស្វយ័តចំនួន ៣)[13] ថាជា *"មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ"* គឺជាការលើកឡើងដោយមិនសមហេតុសមផលយ៉ាងជាក់ច្បាស់ ។

ឃ) បន្ទាប់ពីបានធ្វើការវិភាគយ៉ាងលម្អិតលើភស្តុតាងដែលមាន សហចៅក្រមស៊ើបអង្កេតមិនអាចមើលរំលងបញ្ញត្តិនៃវិធាន ៥៥ (១) ដែលបើកឱ្យមានការស៊ើបសួរចំពោះឧក្រិដ្ឋកម្ម *"ដែលស្ថិតនៅ*

---

[10] D2 ដីកាចាត់ឱ្យស៊ើបសួរជំនួស ចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១០ ។

[11] D1 ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីររបស់សហព្រះរាជអាជ្ញាទាក់ទងទៅនឹងកងទ័ពបដិវត្តកម្ពុជា ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ កថាខណ្ឌ ៩៦ ។

[12] D23 សំណើលើកទី ២ របស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបំពេញកិច្ចស៊ើបសួរបន្ថែមពាក់ព័ន្ធ នឹងលោក ស៊ូ មេត ព្រមទាំងពាក់ព័ន្ធនឹងទីកន្លែងប្រព្រឹត្តបទល្មើស ចុះថ្ងៃទី ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១១ កថាខណ្ឌ ១២ ។ D24 សំណើបំពេញកិច្ចស៊ើបសួរលើកទីបីរបស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទិននឹង មាស មុត និងទីតាំងឧក្រិដ្ឋកម្មដែលពាក់ព័ន្ធ ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១១ កថាខណ្ឌ ១៩ ។

[13] D427 ដីកាដំណោះស្រាយ (សំណុំរឿង ០០២) ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១១ កថាខណ្ឌ ១២៩ ។

*ក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ"* តែប៉ុណ្ណោះ ។ ការណ៍នេះមានន័យថា ការស៊ើបសួរដែលទាក់ទងនឹងយុត្តាធិការជាមូលដ្ឋាន ដែលមានចែងក្នុងមាត្រា ២ នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក គឺជាកិច្ចការជាអាទិភាព ។ ការបន្តការបំពេញកិច្ចស៊ើបសួរបន្ថែមនឹងមិនធ្វើឱ្យមានការផ្លាស់ប្ដូរការវិភាគរបស់យើងអំពីបញ្ហានោះទេ ប៉ុន្តែវានឹងបណ្ដាលឱ្យមានការប្រើប្រាស់ធនធានតុលាការក្នុងលក្ខណៈដែលមិនចាំបាច់ និងមិនទទួលខុសត្រូវ ។

III - សេចក្ដីសម្រេច

**អាស្រ័យហេតុនេះ សហចៅក្រមស៊ើបអង្កេតសម្រេចៈ**

៩. **បដិសេធ** សំណើសុំដែលដាក់ឡើងវិញ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១១

សហចៅក្រមស៊ើបអង្កេត

**យូ ប៊ុនឡេង** **Dr. Siegfried BLUNK**